**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៥៦ . អនក្រ . បក**

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

### សម្រេច

**មាត្រា១._**

ត្រូវបានកំណត់តំបន់ទ្រនាប់សត្វឆ្លងកាត់ រវាងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" និងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ជាប់ផ្លូវជាតិលេខ៤ លើផ្ទៃដីចំនួន ២៩០ហិកតា (ពីររយកៅសិបហិកតា) សម្រាប់ផ្តល់ជូនក្រុមហ៊ុន យន់ ឃាង មីនើរ៉ល(ខេមបូឌា) (YUN KHEAN MINERALS (CAMBODIA) Co., Ltd) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ទេសចរណ៍ និងផ្ទៃដីចំនួន ១០ហិកតា(ដប់ហិកតា) ទៀត សម្រាប់រៀបចំជាវិទ្យាស្ថានបរិស្ថាន និងថ្នាលបណ្តុះកូនឈើរបស់ក្រសួងបរិស្ថាន ទៅជាតំបន់ប្រើប្រាស់ដោយចីរភាពរបស់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" ខេត្តកំពង់ស្ពឺ ដូចមានផែនទី និងនិយាមកាជូនភ្ជាប់មកជាមួយ។

**មាត្រា២._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ